ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

លេខ ១២៣៥ កសក

រាជធានីភ្នំពេញ, ថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ២០១៧

**សូមគោរពជូន**
**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**
**នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា**

**កម្មវត្ថុ ៖** របាយការណ៍ប្រចាំសប្តាហ៍ស្តីពី សភាពការណ៍ល្បឿនការងារបង្កបង្កើនផលនិងល្បឿនការងារប្រមូលផលដំណាំរដូវប្រាំងឆ្នាំ២០១៦-២០១៧។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុខាងលើ ខ្ញុំបាទសូមអនុញ្ញាតជម្រាបជូន **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ជាទីគោរពដ៏ខ្ពង់ខ្ពស់មេត្តាជ្រាប អំពីសភាពការណ៍ល្បឿនការងារបង្កបង្កើនផលនិងល្បឿនការងារប្រមូលផលដំណាំរដូវប្រាំងឆ្នាំ២០១៦-២០១៧ គិតត្រឹមថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៧ មានដូចតទៅ ៖

**I. ល្បឿនការងារបង្កបង្កើនផលស្រូវរដូវប្រាំងឆ្នាំ២០១៦-២០១៧** (ដូចមានតារាងជូនភ្ជាប់)៖

**ក-ការងារដាំដុះ ៖**

- លទ្ធផលភ្ជួររាស់រៀបចំដីសម្រេចបានចំនួន ៥៤៧ ៤៩៥ហ.ត លើសឆ្នាំមុនចំនួន ១៦ ៨៥៣ហ.ត ក្នុងនោះ ភ្ជួររាស់ដោយគោ ក្របីចំនួន ១៤ ០៧២ហ.តស្មើនឹង ២,៥៧% និងដោយគ្រឿងយន្តចំនួន ៥៣៣ ៤២៣ហ.តស្មើនឹង ៩៧,៤៣%
- សាបបានសរុបចំនួន ៥៥៤ហ.ត តិចជាងឆ្នាំមុនចំនួន ៦០៩ហ.ត
- ស្ទូងនិងព្រោះសម្រេចបានចំនួន ៤៨១ ៤៧២ហ.ត ស្មើនឹង ១១១,០០%នៃផែនការ ៤៣៣ ៧៥៥ហ.ត តិចជាងឆ្នាំមុន ២ ៤៦១ហ.ត។

ខ- ល្បឿនការងារប្រមូលផលស្រូវរដូវប្រាំងឆ្នាំ២០១៦-២០១៧ ( ដូចមានតារាងជូនភ្ជាប់) ៖

ក្នុងសប្តាហ៍នេះ ការងារប្រមូលផលស្រូវប្រាំងសម្រេចបានចំនួន **៨១ ១៧៥ហ.ត** ស្មើនឹង ១៦,៨៦% នៃផ្ទៃដីអនុវត្តបានចំនួន ៤៨១ ៤៧២ហ.ត ដោយទទួលបានបរិមាណផលសរុបចំនួន ៣៥៣ ៦០០តោន តិចជាងឆ្នាំមុន ៤៩៩ ៥៤៦ តោន។ ទិន្នផលគិតជាមធ្យមទទួលបាន ៤,៣៥៦តោន/ហ.ត លើសឆ្នាំមុន ២១គ.ក្រ/ហ.ត។

**II. ល្បឿនការងារបង្កបង្កើនផលដំណាំរួមផ្សំនិងដំណាំឧស្សាហកម្មរដូវប្រាំងឆ្នាំ២០១៦-២០១៧** (ដូចមានតារាងជូនភ្ជាប់)៖

ក- ផ្ទៃដីដំណាំរួមផ្សំ អនុវត្តបានចំនួន ៧៩ ៩៥៣ហ.ត ស្មើនឹង ៩៩,៣៣% នៃផែនការ ៨០ ៤៩៤ហ.ត លើសឆ្នាំមុន ៣ ៥៣៩ហ.ត។

ខ -ផ្ទៃដីដំណាំឧស្សាហកម្ម អនុវត្តបានចំនួន ១១ ០១៨ហ.ត ស្មើនឹង ៧៧,៥៤% នៃផែនការ ១៤ ២១០ហ.ត តិចជាងឆ្នាំមុន ១ ២៦៥ហ.ត។

**III. សេចក្តីសន្និដ្ឋាន**

ជារួមក្នុងសប្តាហ៍នេះ ពិនិត្យឃើញថា ល្បឿនការងារបង្កបង្កើនផលស្រូវរដូវប្រាំង ទទួលបានលទ្ធផលល្អប្រសើរ ជាពិសេសដំណាំស្រូវសម្រេចបាន **១១១,០០%**នៃផែនការ ៤៣៣ ៧៥៥ហ.ត។ រីឯទិន្នផលគឺ ទទួលបាន៤,៣៥៦តោន/ហ.ត

អាស័យដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា
N° 200 Preah Norodom Blvd., Sangkat Tonle Basak, Khan Chamkarmon, Phnom Penh, Cambodia
ទូរស័ព្ទលេខ : (០២៣) ៧២៦ ១២៨ / ៧២៦ ១២៩ ទូរសារលេខ : (៨៥៥) ២៣-២១៧ ៣២០
Phone : (023) 726 128 / 726 129, Fax : (855) 23 - 217 320

លើសឆ្នាំមុនចំនួន ២១ត.ក្រ/ហ.ត។ ទន្ទឹមនឹងនោះ ប្រជាកសិករបាននិងកំពុងមមាញឹកដំណើរការច្រូតកាត់ ឲ្យទាន់ពេលវេលាប្រមូលផល ដើម្បីជៀសវាងការបាត់បង់ផលក្នុងពេលច្រូតកាត់ហើយ។ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មានវិធានការបន្តជំរុញការអប់រំណែនាំដល់ប្រជាកសិករ ឲ្យខិតខំបង្កើនបន្ថែមទៀតលើការថែទាំដំណាំស្រូវប្រាំង ក៏ដូចជាដំណាំផ្សេងៗទៀត នៅទីកន្លែងដែលមានប្រភពទឹកស្រោចស្រពគ្រប់គ្រាន់ ពិសេសត្រូវយកចិត្តទុកដាក់ជំរុញការធ្វើកសិកម្មចម្រុះ និងការរៀបចំទុកដាក់ក្រោយពេលប្រមូលផល ឲ្យបានសមស្របតាមលក្ខណៈបច្ចេកទេស។ ជាមួយនេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានចេញសេចក្ដីណែនាំលេខ១០២ សណន.កសក ចុះថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៧ ដើម្បីអនុវត្តវិធានការការពារនិងទប់ស្កាត់ភ្លើងព្រៃ និងភ្លើងឆេះស្រូវជាយថាហេតុ ។

ក្រសួងនៅបន្តពិនិត្យតាមដានសុខភាពសត្វ ការចាក់វ៉ាក់សាំងការពារជំងឺឆ្លងសត្វផ្សេងៗ និងចលនាសត្វដោយខុសច្បាប់នៅតាមបណ្ដារាជធានី ខេត្តជាប់ជាប្រចាំ។

សេចក្ដីដូចបានគោរពរាយការណ៍ជូនខាងលើនេះ ខ្ញុំបាទសូម **សម្ដេចតេជោ នាយករដ្ឋមន្ត្រី** ជាទីគោរពដ៏ខ្ពង់ខ្ពស់ មេត្តាជ្រាបដោយក្ដីអនុគ្រោះ។

សូម **សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** មេត្តាទទួលនូវសេចក្ដីគោរពដ៏ជ្រាលជ្រៅបំផុតអំពីខ្ញុំបាទ។

**រដ្ឋមន្ត្រី**
**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**វេង សាខុន**

**ចម្លងជូន ÷**
- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ក្រុមប្រឹក្សាស្ដារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ
- គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ
- ក្រសួងផែនការ
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
  "ដើម្បីជូនជ្រាប"
- ថ្នាក់ដឹកនាំក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
  "ដើម្បីជ្រាប"
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
នាយកដ្ឋានផែនការ និងស្ថិតិ

## ល្បឿនការងារបច្ចូបចង្កើនផលស្រូវរដូវប្រាំងឆ្នាំ២០១៦-២០១៧
(គិតត្រឹមថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៧)

| ល.រ | រាជធានី-ខេត្ត | ផែនការ (ហ.ត) | ផ្ទៃដីភ្ជួររាស់ | | | | | ផ្ទៃដីសាប (ហ.ត) | ផ្ទៃដីស្ទូង និងព្រោះ (ហត) | | | ភាគរយ | ថ្ងៃខែរាយការណ៍ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | សរុប (ហ.ត) | គោ-ក្របី | | គ្រឿងយន្ត | | | សន្ទូង | ពង្រោះ | សរុប | | |
| | | | | ហ.ត | % | ហ.ត | % | | | | | | |
| 01 | បន្ទាយមានជ័យ | 17,870 | 22,771 | - | - | 22,771 | 100.00 | 1 | 30 | 22,306 | 22,336 | 124.99 | បញ្ចប់ |
| 02 | បាត់ដំបង | 16,400 | 13,628 | - | - | 13,628 | 100.00 | - | - | 13,627 | 13,627 | 83.09 | 08-02-2017 |
| 03 | កំពង់ចាម | 42,000 | 42,379 | 11,383 | 26.86 | 30,996 | 73.14 | 115 | 1,129 | 41,024 | 42,153 | 100.36 | 02-02-2017 |
| 04 | កំពង់ឆ្នាំង | 30,700 | 36,536 | 50 | 0.14 | 36,486 | 99.86 | 291 | 1,678 | 34,624 | 36,302 | 118.25 | 06-02-2017 |
| 05 | កំពង់ស្ពឺ | 550 | 568 | 60 | 11 | 508 | 89.44 | 6 | 15 | 145 | 160 | 29.09 | 06-02-2017 |
| 06 | កំពង់ធំ | 36,000 | 48,472 | - | - | 48,472 | 100.00 | 12 | 142 | 48,330 | 48,472 | 134.64 | 07-02-2017 |
| 07 | កំពត | 7,000 | 6,207 | - | - | 6,207 | 100.00 | 1 | 5 | 6,115 | 6,120 | 87.43 | 06-02-2017 |
| 08 | កណ្ដាល | 55,800 | 61,226 | 393 | 0.64 | 60,833 | 99.36 | - | - | 52,681 | 52,681 | 94.41 | 06-02-2017 |
| 09 | កោះកុង | - | - | | - | | - | | | | - | - | |
| 10 | ក្រចេះ | 14,000 | 14,990 | 1,489 | 9.93 | 13,501 | 90.07 | 21 | 3,427 | 10,597 | 14,024 | 100.17 | បញ្ចប់ |
| 11 | មណ្ឌលគិរី | | - | | - | | - | | | | - | - | |
| 12 | ភ្នំពេញ | 1,150 | 241 | 88 | 37 | 153 | 63.49 | 10 | 45 | 134 | 179 | 15.57 | 07-02-2017 |
| 13 | ព្រះវិហារ | 130 | 18 | | - | 18 | 100 | | | 18 | 18 | 13.85 | បញ្ចប់ |
| 14 | ព្រៃវែង | 75,000 | 78,721 | - | - | 78,721 | 100.00 | - | - | 78,721 | 78,721 | 104.96 | 06-02-2017 |
| 15 | ពោធិសាត់ | 9,000 | 15,918 | - | - | 15,918 | 100.00 | - | - | 15,714 | 15,714 | 174.60 | 06-02-2017 |
| 16 | រតនៈគីរី | | - | | - | | - | | | | - | - | |
| 17 | សៀមរាប | 20,925 | 21,890 | - | - | 21,890 | 100.00 | 20 | 80 | 21,660 | 21,740 | 103.89 | បញ្ចប់ |
| 18 | ព្រះសីហនុ | | - | | - | | - | | | | - | - | |
| 19 | ស្ទឹងត្រែង | 100 | 7 | - | - | 7 | 100.00 | - | - | 6 | 6 | 6.00 | បញ្ចប់ |
| 20 | ស្វាយរៀង | 20,000 | 20,381 | - | - | 20,381 | 100.00 | - | - | 20,174 | 20,174 | 100.87 | បញ្ចប់ |
| 21 | តាកែវ | 75,000 | 152,271 | 459 | 0.30 | 151,812 | 99.70 | - | - | 97,879 | 97,879 | 130.51 | 06-02-2017 |
| 22 | ឧត្ដរមានជ័យ | 600 | 46 | - | - | 46 | 100.00 | 1 | 7 | 40 | 47 | 7.83 | បញ្ចប់ |
| 23 | កែប | 30 | 35 | - | - | 35 | 100.00 | - | - | 35 | 35 | 116.67 | បញ្ចប់ |
| 24 | ប៉ៃលិន | 1,000 | 665 | | - | 665 | 100.00 | 1 | 5 | 554 | 559 | 55.90 | 07-02-2017 |
| 25 | ត្បូងឃ្មុំ | 10,500 | 10,525 | 150 | 1.43 | 10,375 | 98.57 | 75 | 795 | 9,730 | 10,525 | 100.24 | បញ្ចប់ |
| **សរុប** | | **433,755** | **547,495** | **14,072** | **2.57** | **533,423** | **97.43** | **554** | **7,358** | **474,114** | **481,472** | **111.00** | |
| **តួលេខសប្ដាហ៍មុន** | | **433,755** | **527,081** | **13,978** | **2.65** | **513,103** | **97.35** | **496** | **7,138** | **458,698** | **465,836** | **107.40** | |
| **តួលេខឆ្នាំមុន** | | **417,325** | **530,642** | **17,313** | **3.26** | **513,329** | **96.74** | **1,163** | **9,474** | **474,459** | **483,933** | **115.96** | |
| **ប្រៀបធៀបឆ្នាំមុន** | | **16,430** | **16,853** | **-3,241** | **-0.69** | **20,094** | **0.69** | **-609** | **-2,116** | **-345** | **-2,461** | | |

បានឃើញនិងឯកភាព
ប្រធាននាយកដ្ឋានផែនការនិងស្ថិតិ

ភ្នំពេញ, ថ្ងៃទី ០៨ ខែកុម្ភៈ ឆ្នាំ២០១៧
ប្រធានការិយាល័យស្ថិតិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
នាយកដ្ឋានផែនការ និង ស្ថិតិ

# ល្បឿនការងារប្រមូលផលស្រូវរដូវប្រាំងឆ្នាំ ២០១៦-២០១៧

(គិតត្រឹមថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៧)

| ល.រ | រាជធានី-ខេត្ត | ផ្ទៃដីអនុវត្ត (ហត) | ផ្ទៃដីប្រមូលផល (ហត) | ទិន្នផល (តោន/ហ.ត) | បរិមាណផល (តោន) | ភាគរយ (%) | ថ្ងៃខែរាយការណ៍ |
|---|---|---|---|---|---|---|---|
| 01 | បន្ទាយមានជ័យ | 22,336 | 10,731 | 4.424 | 47,479 | 48.04 | 06-02-2017 |
| 02 | បាត់ដំបង | 13,627 | 5,178 | 3.764 | 19,492 | 38.00 | 08-02-2017 |
| 03 | កំពង់ចាម | 42,153 | 6,690 | 4.062 | 27,172 | 15.87 | 02-02-2017 |
| 04 | កំពង់ឆ្នាំង | 36,302 | 1,937 | 4.241 | 8,215 | 5.34 | 06-02-2017 |
| 05 | កំពង់ស្ពឺ | 160 | | - | | - | |
| 06 | កំពង់ធំ | 48,472 | 2,574 | 4.270 | 10,990 | 5.31 | 07-02-2017 |
| 07 | កំពត | 6,120 | | - | | - | |
| 08 | កណ្ដាល | 52,681 | 1,114 | 3.976 | 4,429 | 2.11 | 06-02-2017 |
| 09 | កោះកុង | - | | - | | - | |
| 10 | ក្រចេះ | 14,024 | 8,695 | 4.286 | 37,267 | 62.00 | 06-02-2017 |
| 11 | មណ្ឌលគិរី | - | | - | | - | |
| 12 | ភ្នំពេញ | 179 | | - | | - | |
| 13 | ព្រះវិហារ | 18 | | - | | | |
| 14 | ព្រៃវែង | 78,721 | 16,139 | 4.868 | 78,561 | 20.50 | 06-02-2017 |
| 15 | ពោធិ៍សាត់ | 15,714 | 1,813 | 3.975 | 7,207 | 11.54 | 06-02-17 |
| 16 | រតនគិរី | - | | - | | - | |
| 17 | សៀមរាប | 21,740 | 1,745 | 3.091 | 5,395 | 8.03 | 07-02-17 |
| 18 | ព្រះសីហនុ | - | | - | | - | |
| 19 | ស្ទឹងត្រែង | 6 | | - | | | |
| 20 | ស្វាយរៀង | 20,174 | 6,419 | 4.200 | 26,960 | 31.82 | 08-02-2017 |
| 21 | តាកែវ | 97,879 | 15,500 | 4.503 | 69,800 | 15.84 | 06-02-2017 |
| 22 | ឧត្ដរមានជ័យ | 47 | | - | | | |
| 23 | កែប | 35 | | - | | - | |
| 24 | ប៉ៃលិន | 559 | | - | | - | |
| 25 | ត្បូងឃ្មុំ | 10,525 | 2,640 | 4.028 | 10,634 | 25.08 | 03-02-2017 |
| **សរុប** | | **481,472** | **81,175** | **4.356** | **353,600** | **16.86** | |
| **តួលេខសប្ដាហ៍មុន** | | **465,836** | **42,052** | **4.340** | **182,526** | **9.03** | |
| **តួលេខឆ្នាំ២០១៥-១៦** | | **483,933** | **196,788** | **4.335** | **853,146** | **40.66** | |
| **ប្រៀបធៀបឆ្នាំមុន** | | **-2,461** | **-115,613** | **0.021** | **-499,546** | **-23.80** | |

បានឃើញនិងឯកភាព
ប្រធាននាយកដ្ឋានផែនការនិងស្ថិតិ

ភ្នំពេញ, ថ្ងៃទី ០៨ ខែកុម្ភៈ ឆ្នាំ២០១៧
ប្រធានការិយាល័យស្ថិតិ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ
នាយកដ្ឋានផែនការនិងស្ថិតិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# ល្បឿនការងារបង្កបង្កើនផលដំណាំរួមផ្សំ និងដំណាំឧស្សាហកម្មរដូវប្រាំងឆ្នាំ២០១៦-២០១៧

(គិតត្រឹមថ្ងៃទី០៨ ខែកម្ភៈ ឆ្នាំ២០១៧)

| ល.រ | រាជធានី-ខេត្ត | ពោត (ហ.ត) | | | | ដំឡូងឈើ (ហ.ត) | | ដំឡូងជ្វា (ហ.ត) | | បន្លែគ្រប់មុខ (ហ.ត) | | សណ្តែកបាយ (ហ.ត) | | សរុបរួម (ហ.ត) | | ភាគរយ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | ផែនការ | | អនុវត្ត | | ផែនការ | អនុវត្ត | ផែនការ | អនុវត្ត | ផែនការ | អនុវត្ត | ផែនការ | អនុវត្ត | ផែនការ | អនុវត្ត | % |
| | | សរុប | ក្រហម | សរុប | ក្រហម | | | | | | | | | | | |
| 01 | បន្ទាយមានជ័យ | 225 | - | 81 | - | 6,250 | 16,525 | - | 4 | 1,325 | 1,266 | 120 | 9 | 7,920 | 17,885 | 225.82 |
| 02 | បាត់ដំបង | 460 | - | 217 | - | - | - | 50 | 23 | 960 | 559 | 300 | 817 | 1,770 | 1,616 | 91.30 |
| 03 | កំពង់ចាម | 1,010 | 150 | 2,151 | 817 | 20 | 38 | 760 | 489 | 2,380 | 3,094 | 150 | 844 | 4,320 | 6,616 | 153.15 |
| 04 | កំពង់ឆ្នាំង | 1,090 | 170 | 797 | - | 90 | 51 | 230 | 124 | 1,860 | 2,306 | 1,800 | 2,226 | 5,070 | 5,504 | 108.56 |
| 05 | កំពង់ស្ពឺ | 4 | - | 4 | - | - | 2 | - | 18 | 190 | 168 | - | 18 | 194 | 210 | 108.25 |
| 06 | កំពង់ធំ | 130 | - | 223 | - | 90 | - | 60 | 45 | 345 | 339 | 20 | - | 645 | 607 | 94.11 |
| 07 | កំពត | 200 | - | 128 | - | 135 | 11 | 245 | 77 | 590 | 485 | 255 | 240 | 1,425 | 941 | 66.04 |
| 08 | កណ្តាល | 8,101 | 6,620 | 495 | 480 | 225 | 1 | 190 | - | 5,056 | 3,698 | 4,307 | 3,111 | 17,879 | 7,305 | 40.86 |
| 09 | កោះកុង | 27 | - | | | 3 | | 5 | | 60 | | - | | 95 | - | - |
| 10 | ក្រចេះ | 1,800 | 1,700 | 6,966 | 6,725 | - | - | 80 | 106 | 420 | 620 | 40 | 73 | 2,340 | 7,765 | 331.84 |
| 11 | មណ្ឌលគិរី | - | - | | | - | | - | | - | 474 | - | | - | 474 | |
| 12 | ភ្នំពេញ | 130 | - | 38 | - | - | 5 | - | 4 | 342 | 84 | - | 5 | 472 | 136 | 28.81 |
| 13 | ព្រះវិហារ | - | - | | | - | | - | | 782 | | - | | 782 | - | - |
| 14 | ព្រៃវែង | 1,825 | 1,825 | 5,274 | 5,270 | 200 | - | 10 | 5 | 790 | 623 | 1,425 | 1,856 | 4,250 | 7,758 | 182.54 |
| 15 | ពោធិ៍សាត់ | 200 | 100 | 148 | - | 850 | 4,442 | 350 | 6 | 500 | 324 | 300 | 42 | 2,200 | 4,962 | 225.55 |
| 16 | រតនគិរី | | | | | | | | | | | | | - | - | - |
| 17 | សៀមរាប | 830 | - | 635 | - | 2,490 | 1,645 | 265 | 255 | 2,040 | 1,405 | 1,850 | 2,270 | 7,475 | 6,210 | 83.08 |
| 18 | ព្រះសីហនុ | 35 | | | | 140 | | 20 | | 175 | 409 | - | - | 370 | 409 | 110.54 |
| 19 | ស្ទឹងត្រែង | 250 | - | 139 | - | - | | - | 51 | 450 | 132 | 500 | 110 | 1,200 | 432 | 36.00 |
| 20 | ស្វាយរៀង | - | - | - | - | 7,100 | 404 | 110 | - | 1,170 | 1,143 | - | - | 8,380 | 1,547 | 18.46 |
| 21 | តាកែវ | 232 | - | 90 | - | 398 | 126 | 110 | 215 | 648 | 755 | - | 69 | 1,388 | 1,255 | 90.42 |
| 22 | ឧត្តរមានជ័យ | 9 | - | | | 0 | | - | | 65 | | - | | 74 | - | - |
| 23 | កែប | 150 | 30 | 67 | 5 | 30 | 5 | 100 | 110 | 200 | 120 | - | - | 480 | 302 | 62.92 |
| 24 | ប៉ៃលិន | 2,005 | 2,000 | 298 | - | 1,500 | | | | 15 | | 1,000 | 26 | 4,520 | 324 | 7.17 |
| 25 | ត្បូងឃ្មុំ | 5,210 | 8,942 | 5,575 | 5,420 | - | 70 | 400 | 490 | 1,145 | 1,075 | 490 | 485 | 7,245 | 7,695 | 14,700 |
| | សរុប | 23,923 | 21,537 | 23,326 | 18,717 | 19,521 | 23,325 | 2,985 | 2,022 | 21,508 | 19,079 | 12,557 | 12,201 | 80,494 | 79,953 | 99.33 |
| | តួលេខសប្តាហ៍មុន | 23,923 | 21,537 | 22,840 | 18,668 | 19,521 | 22,285 | 2,985 | 2,015 | 21,508 | 15,360 | 12,557 | 8,154 | 80,494 | 70,654 | 87.78 |
| | តួលេខឆ្នាំមុន | 10,504 | 188 | 23,452 | 18,334 | 4,174 | 18,938 | 4,116 | 2,033 | 11,804 | 18,483 | 12,100 | 13,508 | 42,698 | 76,414 | 178.96 |
| | ប្រៀបធៀបឆ្នាំមុន | 13,419 | 21,349 | -126 | 383 | 15,347 | 4,387 | -1,131 | -11 | 9,704 | 596 | 457 | -1,307 | 37,796 | 3,539 | -79.64 |

| ល.រ | រាជធានី-ខេត្ត | សណ្តែកដី (ហ.ត) | | សណ្តែកសៀង (ហ.ត) | | ល្ង (ហ.ត) | | អំពៅ (ហ.ត) | | ក្រចៅ (ហ.ត) | | ថ្នាំជក់ (ហ.ត) | | សរុបរួម (ហ.ត) | | ភាគរយ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | ផែនការ | អនុវត្ត | ផែនការ | អនុវត្ត | ផែនការ | អនុវត្ត | ផែនការ | អនុវត្ត | ផែនការ | អនុវត្ត | ផែនការ | អនុវត្ត | ផែនការ | អនុវត្ត | (%) |
| 01 | បន្ទាយមានជ័យ | - | - | - | - | - | - | 110 | 106 | - | 35 | - | - | 110 | 141 | 128.18 |
| 02 | បាត់ដំបង | 100 | 17 | - | - | 100 | 70 | 30 | 37 | - | - | - | | 230 | 124 | 53.91 |
| 03 | កំពង់ចាម | 790 | 428 | - | - | 30 | 548 | 360 | 221 | - | - | 3,380 | 2,564 | 4,560 | 3,761 | 82.48 |
| 04 | កំពង់ឆ្នាំង | 80 | 54 | - | - | 760 | 738 | 60 | 558 | 10 | 24 | 60 | 8 | 970 | 1,382 | 142.47 |
| 05 | កំពង់ស្ពឺ | 48 | 21 | - | | - | | - | 4 | - | | - | | 48 | 25 | 52 |
| 06 | កំពង់ធំ | 199 | 25 | - | - | - | 4 | - | 39 | 39 | - | - | - | 238 | 68 | 28.57 |
| 07 | កំពត | 205 | 96 | - | - | 30 | - | 235 | 124 | - | - | - | - | 470 | 220 | 46.81 |
| 08 | កណ្តាល | 96 | 14 | 50 | 20 | 150 | 2 | 442 | 352 | - | - | - | - | 738 | 388 | 52.57 |
| 09 | កោះកុង | - | | - | | - | | 340 | | - | | - | | 340 | - | - |
| 10 | ក្រចេះ | 120 | 189 | - | - | - | - | 110 | 119 | - | - | - | 1,309 | 230 | 1,617 | 703.04 |
| 11 | មណ្ឌលគិរី | - | | - | | - | | - | | - | | - | | - | - | - |
| 12 | ភ្នំពេញ | - | - | - | - | - | 2 | - | 6 | - | - | - | - | - | 8 | - |
| 13 | ព្រះវិហារ | - | | - | | - | | - | | - | | - | | - | - | - |
| 14 | ព្រៃវែង | 130 | 245 | - | - | 1,025 | - | 175 | 146 | - | - | - | - | 1,330 | 391 | 29.40 |
| 15 | ពោធិ៍សាត់ | 550 | 34 | 50 | - | 200 | - | 720 | 68 | - | | - | | 1,520 | 102 | 6.71 |
| 16 | រតនគិរី | | | | | | | | | | | | | - | - | - |
| 17 | សៀមរាប | - | - | 10 | 10 | 210 | - | 405 | 165 | - | - | - | - | 625 | 175 | 28.00 |
| 18 | ព្រះសីហនុ | | | | | | | 40 | | | | | | 40 | - | - |
| 19 | ស្ទឹងត្រែង | - | 35 | - | - | - | - | - | 60 | 50 | | | 10 | 50 | 105 | |
| 20 | ស្វាយរៀង | - | - | - | - | - | - | 523 | 418 | - | - | - | - | 523 | 418 | 79.92 |
| 21 | តាកែវ | 122 | 35 | - | - | 11 | - | 175 | 124 | - | - | - | - | 308 | 159 | 51.62 |
| 22 | ឧត្តរមានជ័យ | - | | - | | - | | - | | - | | - | | - | - | - |
| 23 | កែប | 100 | 19 | - | - | - | - | 30 | 15 | - | | - | | 130 | 34 | 26.15 |
| 24 | ប៉ៃលិន | 50 | | | 5 | 100 | | 10 | | | | | | 160 | 5 | 3.13 |
| 25 | ត្បូងឃ្មុំ | 230 | 115 | - | - | - | 50 | 20 | 25 | - | - | 1,340 | 1,705 | 1,590 | 1,895 | 119.18 |
| សរុប | | 2,820 | 1,327 | 110 | 35 | 2,616 | 1,414 | 3,785 | 2,587 | 99 | 59 | 4,780 | 5,596 | 14,210 | 11,018 | 77.54 |
| តួលេខសប្តាហ៍មុន | | 2,820 | 1,292 | 110 | 15 | 2,616 | 1,360 | 3,785 | 2,368 | 99 | 59 | 4,780 | 5,179 | 14,210 | 10,273 | 72.29 |
| តួលេខឆ្នាំមុន | | 3,624 | 1,782 | 1,173 | 737 | 2,789 | 1,345 | 3,735 | 2,036 | 80 | 19 | 8,930 | 6,364 | 20,331 | 12,283 | 60.42 |
| ប្រៀបធៀបឆ្នាំមុន | | - 804.00 | -455 | -1,063 | -702 | -173 | 69 | 50 | 551 | 19 | 40.00 | -4,150 | -768 | -6,121 | -1,265 | 17.12 |

បានឃើញ និងឯកភាព

ប្រធាននាយកដ្ឋានផែនការ និងស្ថិតិ

ភ្នំពេញ, ថ្ងៃទី ០៨ ខែកុម្ភៈ ឆ្នាំ ២០១៧

ប្រធានការិយាល័យស្ថិតិ